ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តត្បូងឃ្មុំ

សំណុំរឿងព្រហ្មទណ្ឌលេខ ៖ ៤២០
ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២០
ជំនុំជម្រះលេខ ១៤២
ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២១
សាលក្រមព្រហ្មទណ្ឌលេខ ៥០៣ -ង-
ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២៣

តាងនាមប្រជារាស្ត្រខ្មែរ
សាលាដំបូងខេត្តត្បូងឃ្មុំ

បានបើកសវនាការជំនុំជម្រះជាសាធារណៈ នៅថ្ងៃព្រហស្បតិ៍ ១៤រោច ខែកត្របទ ឆ្នាំថោះ បញ្ចស័ក ពស២៥៦៧ ត្រូវនឹងថ្ងៃទី១២ ខែតុលា ឆ្នាំ២០២៣។

និងប្រកាសសាលក្រមជាសាធារណៈ នៅថ្ងៃពុធ ១១កើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ពស២៥៦៧ ត្រូវនឹងថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២៣។

ដែលមានសមាសភាពដូចតទៅ៖

ចៅក្រមជំនុំជម្រះ

-លោក [redacted] ចៅក្រម នៃសាលាដំបូងខេត្តត្បូងឃ្មុំ

តំណាងអយ្យការ

-លោក [redacted] ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងខេត្តត្បូងឃ្មុំ

ក្រឡាបញ្ជីសវនាការ

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តត្បូងឃ្មុំ

ដើម្បីជំនុំជម្រះលើ៖

ពាក្យបណ្តឹងទាស់ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២៣ របស់លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **ស៊ីណា** ភេទប្រុស អាយុ៣២ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិ[redacted] ខេត្តបន្ទាយមានជ័យ ទីលំនៅបច្ចុប្បន្ននៅភូមិ[redacted] ខេត្តបន្ទាយមានជ័យ ក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ ៤២០ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២០ ដែលជាប់ចោទពីបទ**រំលោភលើទំនុកចិត្តពិសេសដោយអភិបាល** ប្រព្រឹត្តនៅចំណុចភូមិពោធិ៍រោងលិច ឃុំកោងកាង ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា **៣៩១** និងមាត្រា **៣៩៣** កថាខណ្ឌទី១ នៃក្រមព្រហ្មទណ្ឌ។

-ដោយមានលោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted]**ស៊ីណា**។

តំណាងដើមបណ្តឹងរដ្ឋប្បវេណី៖

-ឈ្មោះ[redacted]**ប៊ុនថា** ភេទប្រុស កើតឆ្នាំ១៩៨៨ ជនជាតិខ្មែរ អាសយដ្ឋានបច្ចុប្បន្ននៅភូមិក្រាំងអង្រែង សង្កាត់ក្រាំងធ្នង់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ តំណាងឱ្យគ្រឹះស្ថានឥណទានជនបទ ធិតិមាហ្វាយនែន ម.ក។

-ដោយមានលោកស្រី [redacted] ជាមេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងប្បវេណី។

អន្តហេតុនៃការចោទប្រកាន់មានដូចតទៅ៖

ចាប់ពីអំឡុងឆ្នាំ២០១៨ រហូតដល់ខែកក្កដា ឆ្នាំ២០២០ ជនជាប់ចោទឈ្មោះ [redacted] ស៊ីណា តួនាទីនាយកសាខាគ្រឹះស្ថានឥណទានជនបទ ធិតិមា ហ្វាយនែន ម.ក សាខាខេត្តត្បូងឃ្មុំ ដែលមានទីតាំងស្ថិតនៅភូមិពោធិ៍រោងលិច ឃុំកោងកាង ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ បានចាត់ចែង និងរៀបចំកែប្រែទិន្នន័យក្នុងតារាងសងប្រាក់របស់គ្រឹះស្ថានដូចជា ធ្វើការប្រែលេខគណនីអតិថិជនឱ្យខុសពីលេខរបស់គ្រឹះស្ថាន កែប្រែចំនួនទឹកប្រាក់ដោយកំណត់លើសពីការកំណត់របស់គ្រឹះស្ថាន កែប្រែអត្រាការប្រាក់ដោយកំណត់លើសពីការកំណត់របស់គ្រឹះស្ថានប្រើប្រាស់ឃ្លីហ្គ និងគ្រាខុសពីការ

កំណត់របស់គ្រឹៈស្ថាន ហើយបន្ទាប់ពីចាត់ចែង និងរៀបចំរួច ជនជាប់ចោទរូបនេះបានឱ្យជនជាប់ចោទឈ្មោះ យ៉ន រ៉ា តួនាទីប្រធានមន្ត្រីឥណទានឈ្មោះ [redacted] ឆៃហ៊ាត និងឈ្មោះ [redacted] ជីវ័ន្ត ជាមន្ត្រីឥណទានជាបក្ខពួកខ្លួន ដែលបម្រើការងារក្នុងគ្រឹៈស្ថានខាងលើដែរ ជាអ្នកយកតារាងសងប្រាក់ដែលបានកែប្រែទៅប្រគល់ឱ្យអតិថិជន និងជាអ្នកទទួលសងប្រាក់ពីអតិថិជន ក្នុងគោលបំណងគៃបំបាត់ប្រាក់របស់គ្រឹៈស្ថាន និងអតិថិជនដើម្បីយកប្រាក់ទៅប្រើប្រាស់ផ្ទាល់ខ្លួន រួចក្រុមជនជាប់ចោទបានធ្វើរបាយការណ៍ក្លែងក្លាយគ្រឹៈស្ថានថា អតិថិជនយឺតយ៉ាវក្នុងការសង ជាប់បំណុលស្ថាប័នច្រើនគ្មានលទ្ធភាពសង រត់ចោលផ្ទះ ផ្លាស់ទីលំនៅដោយលក់ផ្ទះទៅរស់នៅខេត្តផ្សេង គ្មានពេលវេលាចុះដោះស្រាយមិនស្គាល់អតិថិជន និងលើកឡើងពីផលវិបាកសេដ្ឋកិច្ចក្នុងអំឡុងពេលមានជម្ងឺកូវីដ១៩។ អំពើប្រព្រឹត្តខាងលើរបស់ក្រុមជនជាប់ចោទបានធ្វើឱ្យគ្រឹៈស្ថានខាតបង់ប្រាក់សរុបចំនួន ៦១៣.៦៩៦.១០០(ប្រាំមួយរយដប់បីលានប្រាំបួនរយហុកសិបប្រាំបួនពាន់ មួយរយរៀល និងខាតបង់ប្រាក់ដែលជាងប្រយោជន៍ផ្សេងៗ ទៀតរបស់គ្រឹៈស្ថានអស់មួយចំនួន។

-**បានឃើញ** សាលក្រមព្រហ្មទណ្ឌលេខ **១៩០** "**គ**" ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២១ របស់សាលាដំបូងខេត្តត្បូងឃ្មុំ។

-**បានឃើញ** ពាក្យបណ្តឹងទាស់ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២៣ របស់លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **ស៊ីណា**។

-**បានឃើញ** សេចក្តីចម្លងពាក្យបណ្តឹងទាស់ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២៣។

-**បានឃើញ** ដីកាសម្រេចចាត់តាំងចៅក្រមជំនុំជម្រះលេខ ៧៦៣/២០២៣ ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២៣ របស់ឯកឧត្តមប្រធានសាលាដំបូងខេត្តត្បូងឃ្មុំ។

-**បានឃើញ** សាលក្រមមុនអង្គសេចក្តីលេខ **៤៣៣** "**ង**" ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២៣ របស់សាលាដំបូងខេត្តត្បូងឃ្មុំ។

-**បានឃើញ** ដីកាបង្គាប់ឱ្យបញ្ឈប់ចាប់-ឃុំខ្លួនលេខ **៨២៦/២០២៣** ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២៣ របស់ចៅក្រមជំនុំជម្រះ នៃសាលាដំបូងខេត្តត្បូងឃ្មុំ។

<u>ឆាពេលសវនាការ</u>ៈ

-ជនជាប់ចោទឈ្មោះ [redacted] **ស៊ីណា** បានឆ្លើយថា មូលហេតុដែលខ្លួនប្តឹងទាស់ ដោយសារខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ឡើយ។ ខ្លួនចូលធ្វើការនៅក្នុងមីក្រូហិរញ្ញវត្ថុ ធិតិមា នៅក្នុងឆ្នាំ២០១៥ ហើយបានឡើងតួនាទីជាប្រធានសាខា នៅក្នុងឆ្នាំ២០១៨ ដោយឥណទានបានខូចតាំងពីឆ្នាំ២០១៥ មកម្ល៉េះ។ ឈ្មោះ [redacted] រ៉ា ឈ្មោះ [redacted] ជីវ័ន្ត [redacted] ឆៃហ៊ាត ជាមន្ត្រីឥណទាន និងជាអ្នកប្រមូលលុយយកទៅបង់នៅបេឡា។ ចំពោះលុយចំនួន៦១៣លានរៀលជាង ខ្លួនមិនទទួលស្គាល់ទេ ដោយខាងដើមបណ្តឹងមិនបានចុះទៅជួបអតិថិជនទេ។ អតិថិជនតំចោលស្រុកតាំងពីបុគ្គលិកមកម្ល៉េះ ហើយបុគ្គលិកមកពីភ្នំពេញបានដើរប្រមូលរាល់ថ្ងៃ បែរជាមកទំលាក់កំហុសមកលើខ្លួនទាំងអស់ ដោយហួសការពិត។ ឈ្មោះ [redacted] រ៉ា ឈ្មោះ [redacted] ជីវ័ន្ត ឈ្មោះ [redacted] ឆៃហ៊ាត ពួកគាត់ជាមន្ត្រីឥណទាន រីឯខ្លួនធ្វើការនៅកន្លែង និងជាអ្នកសម្រេចឱ្យអ្នកខ្ចី ហើយឱ្យមន្ត្រីឥណទានជាអ្នកយកលុយទៅបើកឱ្យអតិថិជន។ ក្រុមហ៊ុនគ្មានអាជ្ញាប័ណ្ណទេ ហើយអត្រាការប្រាក់ក្រុមហ៊ុនយកពី១,៥% ទៅ ៣,៥%ក្នុងមួយខែ។ ត្រាប្រើប្រាស់តាំងពីប្រធានមុនមកម្ល៉េះ ក្រុមហ៊ុន ធិតិមា មុនដំបូងជាអង្គការឥណទានភូមិខ្មែរ ដោយប្រើប្រាស់ត្រារបស់អង្គការមករហូត ដោយមិនបានធ្វើបច្ចុប្បន្នក្នុងប្រើប្រាស់ត្រាថ្មីនោះទេ។ ក្រុមហ៊ុនមិនបានចុះបញ្ជី ឬលិខិតអញ្ជើញពីមេខេត្តនោះទេ។ មូលហេតុដែលខ្លួនធ្វើបុគ្គលិក ធិតិមា ដោយសារបៀនចប់ ក៏រកការងារធ្វើសិន ដោយមិនបានគិតថាត្រឹមត្រូវ ឬមិនត្រឹមត្រូវ។ ពួកខ្លួនឈប់ធ្វើការ នៅពេលក្រុមហ៊ុន បានប្តឹងពួកខ្លួន។ នៅក្រុមហ៊ុន មានមន្ត្រីឥណទានចំនួន ៣នាក់ ហើយឈ្មោះ [redacted] ប៊ុនថា ក៏ជាអ្នកដើរយកលុយពីអតិថិជនដែរ ក្រៅពីពួកខ្លួន។ នៅ ធិតិមា ពុំមានគណនេយ្យទេ។ ខ្លួនជាកំពាក្យសុំធ្វើការងារនៅក្នុងត្បូងឃ្មុំ នៅឆ្នាំ២០១៥ បន្ទាប់ពីដាក់ពាក្យបានរយៈពេលប្រហែលកន្លះទៅ១ខែ ទើបបានចូលធ្វើការ ដោយមានបុគ្គលិកចូលធ្វើការចំនួន៥នាក់ ដោយខ្លួនមានតួនាទីជាមន្ត្រីឥណទាន ដើរផ្សព្វផ្សាយ ប្រមូលប្រាក់ ទំលាក់ទុនឱ្យអតិថិជន ហើយឈ្មោះ [redacted] សុភា ជាមេរបស់ខ្លួន។ ខ្លួនចូលធ្វើការនៅខេត្តត្បូងឃ្មុំ តាមរយៈឈ្មោះ [redacted] ប៊ុនៃ គឺក្នុងឆ្នាំ២០១៥ ដល់ឆ្នាំ២០១៨ ហើយធ្វើការងារបាន៣ឆ្នាំ ខ្លួនក៏ឡើងជាប្រធានសាខា ដោយឈ្មោះ [redacted] សុភា ត្រូវចេញ។

Scanned with CamScanner

ឯកសារផ្សេងៗមាននៅក្នុងកុំព្យូទ័រស្រាប់តែ ហើយខាងលើអាចមើលឃើញទិន្នន័យនានាបាន ហើយថ្នាក់លើតែងតែចុះមកមើល និងផ្ទៀងផ្ទាត់ មួយខែម្តង ឬពីរម្តង តាមគោលការណ៍របស់ក្រុមហ៊ុនជានិច្ច។ ដោយម្នាក់ៗទទួលខុសត្រូវតាមតួនាទីរៀងៗខ្លួន។ តាមគោលការណ៍នៅពេលមានការខ្វីប្រាក់ (Loan) គឺធ្វើពីក្រោមមកខ្លួន ហើយខ្លួនបញ្ជូនទៅលើ តាមរយៈស្តេនបញ្ជូន ហើយមានធ្វើរបាយការណ៍រៀងរាល់ខែ។ រាល់ការរៀបចំឯកសារឱ្យអតិថិជនខ្វីប្រាក់ឈ្មោះ [redacted]ភ៉ា ឈ្មោះ [redacted] ធៃហ៊ាត ជាអ្នករៀបចំ រួចយកមកឱ្យខ្លួនចុះហត្ថលេខា រួចស្តេនបញ្ជូនទៅថ្នាក់លើ។ បន្ទាប់ពីអនុម័តរួចរាល់ ក៏ទំលាក់តាមម៉េលមកវិញ ពេលខ្លះមានអង្គការភូមិខ្មែរ ពេលខ្លះធិតិមា ដោយពុំមានប្រថាប់ត្រាទេ។ ក្នុងពេលខ្លួនមានតួនាទីប្រធាន ក្រុមហ៊ុនមិនបានធ្វើបច្ចុប្បន្នឱ្យប្រើត្រា ធិតិម៉ាទេ។ ខ្លួនមិនបានចុះទៅប្រមូលប្រាក់ពីអតិថិជនឡោះយ ហើយខ្លួនក៏មិនបានបោះត្រា ធិតិម៉ា នោះដែរ។ ចន្លោះពេលគេប្តឹងខ្លួន ខ្លួនស៊ែនៅជាយដែន ហើយពេលនោះមានជំងឺកូវីដមិនបានចូលមកឆ្លើយបំភ្លឺតាមការកោះហៅរបស់តុលាការទេ។ របាយការណ៍ប្រចាំត្រីមាសមិនមានធ្វើទេ ធ្វើតែរបាយការណ៍ប្រចាំខែតែប៉ុណ្ណោះ ដោយមានចុះហត្ថលេខា ទទួលរបាយការណ៍ត្រឹមត្រូវ។ ចំពោះរបាយការណ៍ប្រចាំថ្ងៃ ប្រចាំខែ ប្រចាំឆ្នាំ គឺបោះត្រាអង្គការទេ ដោយខាងលើមិនបានធ្វើបច្ចុប្បន្នភ្ជាប់ឱ្យខ្លួនទេ។ ខ្លួនពុំបានសន្យាសងប្រាក់ជាមួយដើមបណ្តឹងទេ ខ្លួនមិនយកទេ ខ្លួនមិនបានប៉ះពាល់លុយរបស់ ធិតិម៉ា ទេ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ប៊ុនថា បានឆ្លើយថា ខ្លួនមានតួនាទីជានាយប្រតិបត្តិនៅក្រុមហ៊ុន មានហានៈជាអភិបាល។ ក្នុងរឿងនេះ ខ្លួនមិនបានប្តឹងឧទ្ធរណ៍ទេ ដោយសារមិនយល់អំពីផ្លូវច្បាប់ ដោយសុខចិត្តទទួលយកសាលក្រមនេះ។ ខ្លួនបានប្តឹងទៅតុលាការរដ្ឋប្បវេណីរួចរាល់អស់ហើយ ដោយតុលាការបានសេចក្តីសម្រេចបង្គាប់ឱ្យជនជាប់ចោទសងសំណងការខូចខាតដូចមានបញ្ជាក់ក្នុងសាលក្រមរដ្ឋប្បវេណី។ កាលពីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ តាមការពិនិត្យលើរបាយការណ៍របស់ឈ្មោះ [redacted] ស៊ីណា ឃើញថាមានភាពមិនប្រក្រតី ខ្លួនក៏បានចារលើរបាយការណ៍នោះ ហើយនៅថ្ងៃទី១ ដល់ថ្ងៃទី១៣ ខ្លួនក៏បានឱ្យមន្ត្រីសវនាការចុះមកពិនិត្យ ឃើញថា ឡហ្គូផ្សេង លេខផ្សេង និងបានហៅបុគ្គលិកទៅសាកសួរបើដង តែពួកគេមិនបានឆ្លើយសារភាពទេ។ ខ្លួនមិនបានដើរប្រមូលលុយពីអតិថិជននោះទេ នៅថ្ងៃទី០១ ខែតុលា ឆ្នាំ២០២០ ខ្លួនមកខេត្តត្បូងឃ្មុំ ម្តង និងបានហៅជនជាប់ចោទសួរនាំ ប៉ុន្តែជនជាប់ចោទមិនសារភាពនោះទេ។ ជនជាប់ចោទមិនមានភាពខ្លាហ៊ាន បែរជាឱ្យកូនចៅជាប់ទោសទៅវិញ។ តុលាការបានរក្សាការពារផ្ទះរបស់គាត់ ដែលជាប់ពាក់ព័ន្ធនឹងរកស៊ីឥណទានផងដែរ។ ឈ្មោះ [redacted] បូរិន បានហៅខ្លួនមកចចាជាមួយគាត់ និងសន្យាសងប្រាក់ ៦៣០លានរៀលជាង ក្នុងរយៈពេល២សប្តាហ៍។ ចេតនារបស់ជនជាប់ចោទ បានសារភាពទទួលស្គាល់នូវទង្វើរបស់គាត់ និងសុំសងលុយរបស់ខ្លួន ក្នុងរយៈពេល ២ឆ្នាំ ៦ខែ និងបានសុំទីស្នាក់ការរបស់ខ្លួន ទៅរកស៊ីទៀតផង។ ឯកសារទាក់ទិននឹងឥណទានជនជាប់ចោទមិនបានប្រគល់ជូនខ្លួនទេ ហើយកុំព្យូទ័រក៏បានបំផ្លាញឯកសារចោលអស់ហើយ រីឯទ្វារក្រមជនជាប់ចោទបានចាក់សោជាប់ ជាហេតុធ្វើឱ្យខ្លួនមិនអាចទៅទារលុយពីអតិថិជនបានទេ។ ឯកសារជាមួយអតិថិជនជនជាប់ចោទបានកែប្រែខុសពីការពិតទាំងអស់។ សាលក្រមព្រហ្មទណ្ឌមុនខ្លួនមិនបានប្តឹងឧទ្ធរណ៍ទេ ដោយទុកឱកាសឱ្យគាត់យកលុយមកសងខ្លួនវិញ មិនចង់ឱ្យគាត់ជាប់គុកទេ។ មុនដំបូងជាអង្គការភូមិខ្មែរ បន្ទាប់មកធនាគារបានណែនាំឱ្យចុះបញ្ជី ក៏ចុះបញ្ជីជា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ធិតិម៉ា និងបង់ពន្ធត្រឹមត្រូវ។ ពីមុនមាន គណនេយ្យចំនួន២នាក់។ ជនជាប់ចោទបានចូលនៅដើមឆ្នាំ២០១៥ ហើយបងប្រុសរបស់គាត់ជាអ្នកណែនាំទើបផ្តល់ឱ្យជាអាទិភាព។ នៅពេលអតិថិជនខ្វីលុយ មន្ត្រីឥណទានជាអ្នករៀបចំឯកសារ រួចស្តេនផ្ញើទៅលើឱ្យបើកឡូន (Loan) បន្ទាប់មកក៏ផ្ញើមកឱ្យគាត់វិញ រួចគាត់ក៏ព្រីនចេញ ដើម្បីប្រគល់ឱ្យទៅមន្ត្រីក្រោមឱវាទគាត់។ ក្នុងរយៈពេលកន្លះខែ ទើបចាប់ភាពមិនប្រក្រតីរបស់ជនជាប់ចោទបាន។ នៅពេលចុះពិនិត្យ គាត់បានឱ្យឯកសារពិតឱ្យពិនិត្យមើលពេលបិទបញ្ជីមិនមានប្រតិបត្តិការនោះទេ។ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ កកើតមានបញ្ហាឡើង ទើបនៅថ្ងៃទី១ ខែកក្កដា ដល់ថ្ងៃទី១៣ ខែកក្កដា ទើបខ្លួនរកឃើញភាពមិនប្រក្រតីរបស់ជនជាប់ចោទ។ នៅពេលគាត់ឡើងតំណាងជាប្រធាន មានធ្វើឯកសារផ្ទេរសិទ្ធិឱ្យបំពេញកិច្ចការ និងផ្ទេរសិទ្ធិត្រឹមត្រូវ។ ខ្ញុំពិតជាមានភាពចន្លោះប្រហោងលើទិន្នន័យក្នុងកុំព្យូទ័រ។ បានពីហៀល មកផ្ទៀងផ្ទាត់ ទើបដឹង ជនជាប់ចោទមានចេតនាកៃបំបាត់លុយ ក្រុមហ៊ុន។ ឯកសារខុសការប្រាក់ ឡូន យកមកផ្ទៀងទើបដឹង។ ពេលនោះ ខ្ញុំអត់ដឹង ខ្ញុំមានចេតនា ចង់ទុកពេលឱ្យគាត់ និងអោបក្រសោបគាត់ដែរ។ របាយការណ៍ដែលជនជាប់ចោទបញ្ជូនទៅថ្នាក់លើ គឺស្តេន បានតែមើលលើការចំណាយ តែមិនមានចំណារ

Scanned with CamScanner

ទទួលស្គាល់។ ក្នុងនាមស្ថាប័ន ខាងសវនកម្មបានចុះមកពិនិត្យដែរ តែរកមិនឃើញភាពមិនប្រក្រតីទេ ពេលទៅមើលនៅហៀល ទើបដឹង។ សវនកម្មបានរកឃើញ ត្រង់ចំណុចត្បែងឯកសារអតិថិជន និងការបង់យឺតយ៉ាវរបស់អតិថិជន។ ការខូចខាតមានចំនួន ៦០០ជាងលានរៀល ខាងស្ថាប័នរបស់ខ្លួន (សវនកម្មផ្ទៃក្នុង)ជាអ្នកគិត និងមានការសោកាតគាត់ផងដែរ ដោយមិនមានសវនកម្មខាងក្រៅជាអ្នកគិតនោះទេ។ ឯកសារដែលដាក់មកតុលាការជាឯកសារនៅសេសសល់តែប៉ុណ្ណោះ។ នៅពេលមានសង្ស័យគាត់ហើយ ខ្លួនបានហៅទាំងបីនាក់មកណែនាំ ក៏ដូចមានធ្វើកំណត់ហេតុជាមួយពួកគាត់ដែរ តែពួកគាត់មិនបានសារភាពទេ។ បន្ទាប់មកជនជាប់ចោទបានដឹង ក៏បានប្រមូលឯកសារត្បែងភ្ជាយរបស់ខ្លួនយកមកដុតចោល ហើយឯកសារទាំងនោះនៅសេសសល់តិចតួចទេ ខ្លួនក៏ប្រមូលពីហៀលមកវិញ។ ពាក់ព័ន្ធនឹងកំណត់ហេតុជួបជាមួយ [redacted] ស៊ីណា គាត់បានសារភាព ហើយតាមឆាតក៏ទទួលស្គាល់ដែរ។ ទាក់ទិននឹងបំផ្លាញកស្តុតាង ខ្លួនមានរូបថត និងសាក្សីជាម្ចាស់ផ្ទះ។ ក្នុងឆ្នាំ២០១៧ ដល់ឆ្នាំ២០១៨ អត្រាការប្រាក់ ៣,៥ភាគរយក្នុងមួយខែតាមសាខាផ្សេងគ្នា ទើបអាចទប់ទល់ជាមួយប្រតិបត្តិការបាន តែក្នុងឆ្នាំ២០២០ ខ្លួនមិនបានទំលាក់ឡូន ដែលមានការប្រាក់បែបនឹងទេ។ សវនកម្មលើតែសំណៅដើមទេ។ នៅពេលដាក់ឡូនឱ្យអតិថិជន ក៏មានឡូនផ្ទាល់ខ្លួនរបស់ [redacted] ស៊ីណា និងឡូនរបស់ក្រុមហ៊ុនផងដែរ។ លុយដែលទំលាក់ចូលកុង គឺជាលុយដែលត្រូវប្រមូលត្រឡប់មកវិញ។ អតិថិជន បានបញ្ជាក់ថា លុយខ្វីពី [redacted] ស៊ីណា គាត់មិនដឹងឮជាមួយខ្លួនទេ លុះត្រាឈ្មោះ [redacted] ស៊ីណា មកយក ទើបឱ្យ ធាតុពិតលុយទាំងនោះជាលុយរបស់ក្រុមហ៊ុនទេ។ នៅពេលថ្នាក់លើដឹងពីការកេងប្រវ័ញ្ចលុយរបស់ក្រុមហ៊ុន ជនជាប់ចោទបានព្យាយាមបំផ្លាញកស្តុតាងចោល។

-សាក្សីឈ្មោះ [redacted] ជីវ័ន្ត បានឆ្លើយថា ខ្លួនចូលធ្វើការនៅឆ្នាំ២០១៨ សាខាត្បូងឃ្មុំ មានបុគ្គលិកចំនួន ៦នាក់ បន្ទាប់មកចេញ២នាក់ សល់៤ ដោយមានឈ្មោះ [redacted] ស៊ីណា ជាប្រធានអង្គការ។ ឈ្មោះ [redacted] ភ័ក្ត្រ និងឈ្មោះ [redacted] ឆៃ ហ៊ាត ជាមន្ត្រីឥណទាន។ ខ្លួនមានតួនាទី ជាដើរអ្នកប្រមូលលុយ ផ្សព្វផ្សាយ និងដាក់ខុន។ ពេលចុះផ្សព្វផ្សាយតាមភូមិ ឥណទានមាន៥០ម៉ឺនរៀល, ១លានរៀល អត្រាការប្រាក់ ៣,៥ភាគរយក្នុងមួយខែជាគោលការណ៍របស់ស្ថាប័ន។ ខ្លួនជាមួយនឹងឈ្មោះ [redacted] ឆៃហ៊ាត និងឈ្មោះ [redacted] ភ័ក្ត្រ នៅពេលផ្តល់ប្រាក់កម្ចីឱ្យអតិថិជន ត្រូវឆ្លងកាត់ [redacted] ស៊ីណា មុនដំបូងខ្លួនចូលធ្វើការ មានបេឡា បន្ទាប់មកខ្លួនបេឡាចេញ ខ្លួនក៏ធ្វើជាបេឡាផង ជាអ្នកប្រមូលប្រាក់ផង។ លុយប្រមូលបានរាប់ និងសរសេរឡើង (ធ្វើរបាយការណ៍) រួចយកទៅខុកក្នុងទូដែក មួយអាទិត្យ ទើបយកទៅដាក់នៅធនាគារ។ ខ្លួនបានធ្វើរបាយការណ៍ប្រចាំថ្ងៃ តែរបាយការណ៍ប្រចាំខែខ្លួនមិនបានធ្វើទេ។ ចំពោះរបាយការណ៍ធ្វើទៅថ្នាក់លើ កែវ ស៊ីណា ជាអ្នកធ្វើឡើងទៅថ្នាក់លើ ខ្លួនទទួលបានប្រាក់ខែ១លាន៣០ម៉ឺនរៀល។ ខ្លួនមិនបានធ្វើសកម្មភាពកេងប្រវ័ញ្ចលុយក្រុមហ៊ុននោះទេ។ ក្នុងមួយខែ ខាងក្រុមហ៊ុន បានចុះអធិការកិច្ចជាមួយសាខាមួយដង ឬពីរដង និងចុះទៅហៀលជាមួយខ្លួន និងសួរនាំអតិថិជនផងដែរ។ ចុះមកម្តងពីរនាក់ និងបានចុះហត្ថលេខា បានឃើញលើរបាយការណ៍អធិការផងដែរ។ ខ្លួនធ្វើការទើបតែបានចំនួន៤ខែប៉ុណ្ណោះ ហើយទាមទាររបស់ដើមបណ្តឹងឱ្យខ្លួនសងប្រាក់នោះ ខ្លួនមិនទទួលស្គាល់ទេ។ មុនដំបូងលុយដាក់ចូលទូដែក គឺអ្នកគ្រូបេឡា ក្រោយមកខ្លួនជាយកទៅដាក់ក្នុងទូដែក ហើយនៅពេលមានអធិការកិច្ចចុះមកមើល គឺមិនមានបញ្ហាទេ។ នៅពេលមានអតិថិជនចង់ខ្វីលុយ អតិថិជនត្រូវបំពេញឯកសារ និងមានការបញ្ជាក់មេភូមិ និងមេឃុំ។ បន្ទាប់ពីអ្នកខ្វីលុយបានផ្តិតមេដៃរួចក៏ផ្ញើទៅថ្នាក់លើ ពេលថ្នាក់លើឯកភាព ទើបទំលាក់មកវិញ។ ពាក់ព័ន្ធយកលុយដាក់ក្នុងទូដែករយៈពេល២ខែ និងដាក់នៅធនគារ គឺកុងធនាគាររបស់ឈ្មោះ [redacted] ប៊ុនថា ដោយមានវ៉ែយប័ត្រពីខាងធនាគារត្រឹមត្រូវ។ ឈ្មោះ [redacted] ភ័ក្ត្រ និងឈ្មោះ [redacted] ឆៃ ហ៊ាត មិនដែលយកលុយមកដាក់ទេ ព្រោះសោខ្លួនជាអ្នកកាន់។ ខ្លួនចូលធ្វើការនៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០២០ ខ្លួនធ្វើការបានចំនួន៤ខែ អត់ដែលមានបញ្ហាអ្វីទេ។

<u>សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី:</u>

ក្រោយពីបានស្តាប់ការសាកសួរដេញដោលនាពេលសវនាការ និងពិនិត្យលើឯកសារនៅក្នុងសំណុំរឿង យើងថា កាលពីថ្ងៃសវនាការលើកមុនថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២១ ជនជាប់ចោទឈ្មោះ [redacted] ភ័ក្ត្រ បានឆ្លើយសារភាពទទួលស្គាល់កំហុស និងបានទំលាក់ទៅកំហុសនេះលើឈ្មោះ [redacted] ស៊ីណា ទាំងស្រុង ហើយជនជាប់ចោទឈ្មោះ [redacted] ជីវ័ន្ត ក៏បានឆ្លើយដូចគ្នានឹងចម្លើយរបស់ឈ្មោះ [redacted] ភ័ក្ត្រ ផងដែរ គឺឈ្មោះ [redacted] ស៊ីណា ជាអ្នកបញ្ជា ដោយឈ្មោះ [redacted] ជីវ័ន្ត ក៏

បានដឹងរឿងនេះដែរ ហើយឈ្មោះ [redacted] ស៊ីណា ជាអ្នកបញ្ជាដោយផ្ទាល់ទៅឈ្មោះ [redacted] ជីវ័ន្ត ឱ្យធ្វើ។ ប៉ុន្តែនាពេលនេះ ឈ្មោះ [redacted] ជីវ័ន្ត បែបជាឆ្លើយថា ពុំបានប្រព្រឹត្តទៅវិញ។ ម្យ៉ាងទៀតក្រោយពីប្រព្រឹត្តបទល្មើសរួច ជនជាប់ចោទឈ្មោះ [redacted] ស៊ីណា បានរត់គេចខ្លួន និងគេចវេសពីការទទួលខុសត្រូវចំពោះអំពើល្មើសរបស់ខ្លួន។ ការដែលជនជាប់ចោទឈ្មោះ [redacted] ស៊ីណា ធ្វើបែបនេះបានធ្វើប៉ះពាល់ផ្លូវអាម្មណ៍ និងស្ថានភាពហិរញ្ញវត្ថុរបស់កូនក្តីខ្លួន ហើយការងាររបស់កូនក្តីខ្លួនជាការងារដាក់ឥណទានមកឱ្យថ្នាក់ក្រោម ដើម្បីឱ្យអ្នកក្រោមរ៉ាវតមានការងារធ្វើ។ កូនក្តីខ្លួនមានការបាក់ទឹកចិត្តយ៉ាងខ្លាំងនៅពេលឃើញជនជាប់ចោទឈ្មោះ [redacted] ស៊ីណា ដើរហោះសើ និងមិនខ្លាចច្បាប់ដូច្នេះ។ សំណូមពរ សុំឱ្យតុលាការអនុវត្តវិធានការចាប់ឃុំខ្លួនឈ្មោះ [redacted] ស៊ីណា តាមនីតិវិធីច្បាប់។

<u>សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ៖</u>

ជនជាប់ចោទឈ្មោះ [redacted] ស៊ីណា បានប្តឹងទាស់នឹងសាលក្រមព្រហ្មទណ្ឌលេខ ១៩០ "គ" ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២១ របស់សាលាដំបូងខេត្តត្បូងឃ្មុំ ទាំងមូល ទើបតុលាការដេញដោលលើរឿងនេះ ឃើញថា នាពេលសវនាការជនជាប់ចោទឈ្មោះ [redacted] ស៊ីណា បានបដិសេធថា ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ឡើយ ប៉ុន្តែបើតាមចម្លើយរបស់ជនជាប់ចោទផ្សេងទៀតឃើញថា ជនជាប់ចោទឈ្មោះ [redacted] ស៊ីណា ពិតជាជាប់ពាក់ព័ន្ធប្រាកដមែន។ ប៉ុន្តែបើពិនិត្យចម្លើយរបស់សាក្សីឈ្មោះ [redacted] ជីវ័ន្ត បានបញ្ជាក់ថា លុយដែលប្រមូលបានពីអតិថិជន គឺរាប់ត្រឹមត្រូវ និងបានធ្វើបាយការណ៍ រាយការណ៍ទៅថ្នាក់លើ រួចក៏យកលុយទៅទុកក្នុងទូដែក មួយអាទិត្យ ទើបយកទៅដាក់នៅធនាគារ ហើយក្នុងមួយខែខាងក្រុមហ៊ុន បានឱ្យខាងសនោការចុះមកពិនិត្យនៅសាខាមួយដង ឬពីរដង ផងដែរ គឺមិនមានបញ្ហានោះទេ។ ក្នុងរឿងនេះនៅមានមន្ទិលជាច្រើន ហេតុដូច្នេះស្នើសុំតុលាការសម្រេចតាមឆន្ទានុសិទ្ធិ។

<u>សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ៖</u>

ក្រោយពីបានស្តាប់កំណត់ហេតុចម្លើយរបស់ឈ្មោះ [redacted] ប៊ុនថា, ក្រោយពីបានស្តាប់កំណត់ហេតុចម្លើយរបស់ឈ្មោះ [redacted] ជីវ័ន្ត, ឈ្មោះ [redacted] វ៉ា, ឈ្មោះ [redacted] ឆៃហ៊ាត, ក្រោយពីបានស្តាប់ចម្លើយរបស់ឈ្មោះ [redacted] ស៊ីណា និងក្រោយពីបានពិនិត្យទៅលើសំណុំរឿង ឃើញថាកូនក្តីរបស់ខ្លួន គឺមិនបានប្រព្រឹត្តអំពើ រំលោភលើទំនុកចិត្តពិសេសដោយអកិបាល ដូចការចោទប្រកាន់របស់តំណាងអយ្យការនោះទេ ដោយហេតុថា កូនក្តីខ្លួនឈ្មោះ [redacted] ស៊ីណា បានចូលបំរើការងារនៅគ្រឹះស្ថានឥណទានជនបទ ធិតិមា ហ្វាយនែន ម.ក អំឡុងឆ្នាំ២០១៨ រហូតមកឆ្នាំ២០២០ ក្នុងតួនាទីជានាយកសាខា ក្រោមការតែងតាំងដោយផ្ទាល់មាត់របស់ឈ្មោះ [redacted] ប៊ុនថា ពុំមានលិខិតតែងតែងនោះទេ ក្នុងតួនាទីខាងលើ កូនក្តីខ្លួនបានខិតខំប្រឹងប្រែងបំពេញការកិច្ចជូនក្រុមហ៊ុនយ៉ាងម៉ត់ចត់ ប៉ុន្តែដោយសារតែស្ថានភាពពេលនោះ ស្ថិតនៅក្នុងអំឡុងពេលកូវីដ-១៩ អតិថិជនខ្លះពុំមានលទ្ធភាពសង និងគួបផ្សំនឹងស្ថានភាពកម្ចីចាស់ៗដែលបានខូច និងស្ថិតនៅក្រោមការទទួលខុសត្រូវរបស់នាយកសាខាចាស់នាពេលកន្លងមកផងនោះ ទើបធ្វើឱ្យដើមបណ្តឹងមានភាពមិនសប្បាយចិត្ត អាក់អន់ចិត្តចំពោះកូនក្តីខ្លួន ពិតណាស់នៅក្នុងតួនាទីទោះបីមានកំហុសតិចតួចក្តីដោយអចេតនាក្តី ចង់ ឬមិនចង់ក៏ត្រូវតែទទួលខុសត្រូវ។

ចំពោះការប្តឹងចោទប្រកាន់ថាកូនក្តីខ្លួនរំលោភលើទំនុកចិត្ត ពុំមានភាពត្រឹមត្រូវនោះទេ ដោយសារតែបើតាមចម្លើយរបស់កូនក្តីខ្លួនមុនពេលចុះហត្ថលេខា លើលិខិត និងផ្តល់កម្ចី គឺមានការរៀបចំពីសំណាក់បុគ្គលិក ឈ្មោះ [redacted] ឆៃហ៊ាត និងឈ្មោះ [redacted] ជីវ័ន្ត ព្រមទាំងឈ្មោះ [redacted] វ៉ា ហើយមុនឈានដល់ការ ចុះហត្ថលេខាផ្តល់កម្ចី គឺថ្នាក់លើធ្វើឯកសារមក ដើម្បីចុះហត្ថលេខា ហើយការចុះហត្ថលេខានេះ គឺធ្វើតាមការបញ្ជារ និងអនុញ្ញាតពីថ្នាក់លើទាំងអស់ ហើយបើសិនជាកូនក្តីខ្លួនមានកំហុស គឺកំហុសទាំងនោះគ្រាន់ជាកំហុសដោយអចេតនាព្រោះកូនក្តីខ្លួនមិនបានពិនិត្យគ្រប់ស្រទាប់ជ្រុងជ្រោយទៅលើឯកសារតែប៉ុណ្ណោះ មួយវិញទៀត កូនក្តីខ្លួនក៏មិនបានបញ្ជាឱ្យឈ្មោះ [redacted] ឆៃហ៊ាត និងឈ្មោះ [redacted] ជីវ័ន្ត ធ្វើការកែប្រែ ឬទៅយកលុយពីអតិថិជនឱ្យលើសពីកំណត់នោះទេ។

កូនក្តីខ្លួនមិនបានបង្គាប់បញ្ជាឱ្យបុគ្គលិក ធ្វើការកែប្រែលេខគណនីអតិថិជនឱ្យខុសពីលេខរបស់គ្រឹះស្ថាន, ធ្វើការកែប្រែចំនួនទឹកប្រាក់ដោយកំណត់លើពីការកំណត់របស់គ្រឹះស្ថាន ប្រើប្រាស់ឡូហ្គូ និងត្រាខុសពីការកំណត់របស់គ្រឹះស្ថាន និងមិនបានប្រើប្រាស់ប្រាក់ផ្ទាល់ខ្លួនឱ្យអតិថិជនខ្ចី ដោយប្រើប្រាស់ឡូហ្គូ និងត្រារបស់គ្រឹះស្ថាននោះដែរ ក្នុង

នោះដែរចំពោះគ្រារបស់ក្រុមហ៊ុន គឺដើមបណ្តឹងមិនដែលធ្វើបច្ចុប្បន្នភាពឱ្យកូនក្តីខ្លួនប្រើប្រាស់គ្រាដែលមានឈ្មោះរបស់ក្រុមហ៊ុនធិតិមានោះទេ គឺមានតែ និងឱ្យប្រើប្រាស់តែគ្រាដែលមានឈ្មោះឥណទានភូមិខ្មែរតែប៉ុណ្ណោះ។

ចំពោះឯកសារ តារាងសងប្រាក់កម្ចី របស់ធិតិមា ហ្វាយនែន ម.ក ទាំងអស់ សុទ្ធសឹងតែធ្វើឡើងដោយ ដើមបណ្តឹងខ្លួនឯងសុទ្ធសាធ ដើម្បីយកមកប្តឹងកូនក្តីខ្លួន ហើយរបាយការណ៍ផ្តល់ទុនរបស់វិញ ក៏ធ្វើឡើងដោយខ្លួនឯងដែរ នៅក្នុងរបាយការណ៍នោះផ្តល់ទុនដល់អតិថិជនខ្លះតាំងពីឆ្នាំ២០១៦មកម្ល៉េះ តាំងពីកូនក្តីខ្លួនមិនទាន់ធ្វើការងារផង ត្រង់ចំណុចនេះចំពោះឯកសារទាំងអស់ខាងលើ ពុំគួរឱ្យតុលាការជឿជាក់បាននោះទេ និងយកទៅធ្វើការពិចារណានោះដែរ។

-តាមកំណត់ហេតុចម្លើយរបស់ឈ្មោះ [redacted] ឆៃហ៊ាត និងឈ្មោះ [redacted] ជីវន្ត វិញ ឃើញថា បានឆ្លើយយ៉ាងច្បាស់ថា ពួកគាត់ជាអ្នករៀបចំឯកសារ ផ្តល់កម្ចី និងទៅទារលុយពីអតិថិជន។ មួយវិញទៀតការឆ្លើយទំលាក់កំហុសមកឱ្យកូនក្តីខ្ញុំថាពួកគាត់ធ្វើបញ្ជារពីកូនក្តីខ្លួន គឺគ្រាន់តែជាការឆ្លើយយកល្អខ្លួនឯង និងដើម្បីគេចវេសពីការទទួលខុសត្រូវលើចំពោះកំហុសរបស់ខ្លួនតែប៉ុណ្ណោះ ការពិតគឺពួកគាត់ជាអ្នកបង្ករអោយមានកំហុសចំពោះក្រុមហ៊ុន ។

-ចំពោះការប្តឹងទាមទាររបស់ដើមបណ្តឹងពុំមានភាពច្បាស់លាស់នោះឡើយ ចំពោះចំនួនប្រាក់ ដែលមានការខាតបង់ ហើយរបាយការណ៍ក៏សុទ្ធសឹងតែធ្វើឡើងដោយខ្លួនឯងផ្ទាល់ និងពុំមានស្តាប់នសនែកម្មឯករាជ្យណាមួយដែលទទួលស្គាល់ដោយច្បាប់ ដើម្បីធ្វើការងារនោះឡើយ ហេតុដូច្នេះតុលាការពុំគួរយករបាយការណ៍នោះទៅពិចារណានោះឡើយ។

ដូចនេះឃើញថា កូនក្តីខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់របស់តំណាងអយ្យការ និងការប្តឹងចោទប្រកាន់របស់ដើមបណ្តឹងរដ្ឋប្បវេណីនោះទេ ហើយកំហុសរបស់កូនក្តីខ្លួនកើតដោយសារតែអចេតនាក្នុងការពិនិត្យឯកសារតែប៉ុណ្ណោះ ព្រោះតែការរៀបចំឯកសារ គឺធ្វើឡើយដោយបុគ្គលិកផ្សេង គឺឈ្មោះ [redacted] ឆៃហ៊ាត និងឈ្មោះ [redacted] ជីវន្ត ព្រមទាំងឯកសារមួយចំនួនទៀត គឺធ្វើមកពីថ្នាក់លើ និងការប្រើប្រាស់គ្រា គឺដើមបណ្តឹងអនុញ្ញាតឱ្យប្រើប្រាស់ដែលមានឈ្មោះឥណទានភូមិខ្មែរប៉ុណ្ណោះ និងមិនបានធ្វើបច្ចុប្បន្នភាពឱ្យកូនក្តីខ្លួនប្រើប្រាស់គ្រារបស់ ធិតិមាឡើយតាំងតែពីក្រុមហ៊ុនបានប្តូរឈ្មោះ និងកូនក្តីខ្លួនចាប់ផ្តើមធ្វើការក្នុងតួនាទីនេះ ដូចនេះខ្លួនសុំច្រានចោលការចោទប្រកាន់របស់តំណាងអយ្យការ និងការចោទប្រកាន់របស់ដើមបណ្តឹងរដ្ឋប្បវេណីមកលើកូនក្តីខ្លួន។

យោងតាមមាត្រា ៣៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ វិមតិសង្ស័យត្រូវតែបានជាអត្ថប្រយោជន៍ដល់ជនជាប់ចោទជានិច្ច និងយោងតាមមាត្រា ៤ នៃក្រមព្រហ្មទណ្ឌ បានចែងថា ពុំមានបទល្មើសទេ ប្រសិនបើគ្មានចេតនាប្រព្រឹត្ត។ ដូច្នេះ ស្នើសុំឱ្យតុលាការសម្រេចឱ្យកូនក្តីខ្លួនបានរួចផុតពីបទចោទ។

<u>សំដីចុងក្រោយរបស់ជនជាប់ចោទ</u>

-ជនជាប់ចោទឈ្មោះ [redacted] ស៊ីណា បានឆ្លើយថា ស្នើសុំឱ្យតុលាការសម្រេចឱ្យខ្លួនបានរួចផុតពីបទចោទ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ស៊ីណា
-ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី
-ក្រោយពីបានស្តាប់អំណានចម្លើយរបស់សាក្សី
-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី
-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ
-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ
-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ
-ក្រោយពីបានពិនិត្យកសុតាង និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

<u>សាលាដំបូងខេត្តត្បូងឃ្មុំ</u>

<u>យល់ឃើញថា</u>

១-ពាក្យបណ្តឹងទាស់ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២៣ របស់លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ស៊ីណា ដែលបានប្តឹងទាស់នឹងសាលក្រមព្រហ្មទណ្ឌកំចាំងមុខលេខ ១៩០ "គ"

Scanned with CamScanner

ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២១ របស់សាលាដំបូងខេត្តស្ទឹងឃ្មុំ នោះ បានធ្វើឡើងក្នុងអំឡុងច្បាប់កំណត់ និងស្របតាមមាត្រា **៣៦៨** នៃក្រមនីតិវិធីព្រហ្មទណ្ឌអាចឱ្យតុលាការលើកយកមកជំនុំជម្រះ បាន។

២-នាពេលសវនាការជនជាប់ចោទឈ្មោះ [redacted] **ស៊ីណា** បានឆ្លើយថា មូលហេតុដែលខ្លួនប្តឹងទាស់ ដោយសារខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ឡើយ។ ខ្លួនចូលធ្វើការនៅក្នុងមីក្រូហិរញ្ញវត្ថុ ធិតិមា នៅក្នុងឆ្នាំ២០១៥ ហើយបានឡើងតួនាទីជាប្រធានសាខា នៅក្នុងឆ្នាំ២០១៨ ដោយឥណទានបានខូចតាំងពីឆ្នាំ២០១៥ មកម្ល៉េះ។ ឈ្មោះ [redacted] ប៉ា ឈ្មោះ [redacted] **ជីវ័ន្ត** ហេង ឆៃហ៊ាត ជាមន្ត្រីឥណទាន និងជាអ្នកប្រមូលលុយយកទៅបង់នៅបេឡា។ ចំពោះលុយចំនួន ៦១៣លានរៀលជាង ខ្លួនមិនទទួលស្គាល់ទេ ដោយខាងដើមបណ្តឹងមិនបានចុះទៅជួបអតិថិជនទេ។ អតិថិជនតែចោលស្រុកតាំងពីបុគ្គលិកមកម្ល៉េះ ហើយបុគ្គលិកមកពីភ្នំពេញបានដើរប្រមូលរាល់ថ្ងៃ បែរជាមកចំលាក់កំហុសមកលើខ្លួនទាំងអស់ ដោយហួសការពិត។ ចម្លើយនេះ គ្រាន់តែជាចម្លើយដោះសារដើម្បីចង់គេចវេសពីការទទួលខុសត្រូវតែប៉ុណ្ណោះ មិនអាចឱ្យតុលាការជឿបានឡើយ។ ផ្ទុយទៅវិញបើតាមការពិនិត្យផ្ទៀងផ្ទាត់លើឯកសារនានាដែលមាននៅក្នុងសំណុំរឿង ឃើញថា នៅក្នុងអំឡុងដែលពេលជនជាប់ចោទឈ្មោះ [redacted] **ស៊ីណា** បម្រើការងារឱ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុធិតិមា ហ្វាយនែន ជនជាប់ចោទពិតជាបានធ្វេសប្រហែសធ្វើខូចប្រយោជន៍របស់ដើមបណ្តឹង ប្រាកដមែន។

៣-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ប៊ុនថា** បានឆ្លើយថា ខ្លួនមានតួនាទីជានាយប្រតិបត្តិនៅក្រុមហ៊ុន មានហ៊ុន:ជាអភិបាល។ ក្នុងរឿងនេះ ខ្លួនមិនបានប្តឹងឧទ្ធរណ៍ទេ ដោយសារមិនយល់អំពីផ្លូវច្បាប់ ដោយសុខចិត្តទទួលយកសាលក្រមនេះ។ ខ្លួនបានប្តឹងទៅតុលាការរដ្ឋប្បវេណីរួចរាល់អស់ហើយ ដោយតុលាការបានសេចក្តីសម្រេចបង្គាប់ឱ្យជនជាប់ចោទសងសំណងការខូចខាតដូចមានបញ្ជាក់ក្នុងសាលក្រមរដ្ឋប្បវេណី។ កាលពីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ តាមការពិនិត្យលើរបាយការណ៍របស់ឈ្មោះ [redacted] ស៊ីណា ឃើញថាមានភាពមិនប្រក្រតី ខ្លួនក៏បានចារលើរបាយការណ៍ នោះ ហើយនៅថ្ងៃទី១ ដល់ថ្ងៃទី១៣ ខ្លួនក៏បានឱ្យមន្ត្រីសវនាការចុះមកពិនិត្យ ឃើញថា ឡហ្គូផ្សេង លេខផ្សេង និងបានហៅបុគ្គលិកទៅសាកសួរបើជង តែពួកគេមិនបានឆ្លើយសារភាពទេ។ ចេតនារបស់ជនជាប់ចោទបានសារភាពទទួលស្គាល់នូវទង្វើរបស់គាត់ និងសុំសងលុយរបស់ខ្លួន ក្នុងរយៈពេល ២ឆ្នាំ ៦ខែ និងបានសុំទិស្នាក់ការរបស់ខ្លួន ទៅរកស៊ីទៀតផង។ ឯកសារទាក់ទិននឹងឥណទានជនជាប់ចោទមិនបានប្រគល់ជូនខ្លួនទេ ហើយកុំព្យូទ័រក៏បានបំផ្លាញឯកសារ ចោលអស់ហើយ រីឯថ្នាក្រុមជនជាប់ចោទបានចាក់សោរជាប់ ជាហេតុធ្វើឱ្យខ្លួនមិនអាចទៅទារលុយពីអតិថិជនបានទេ។ ឯកសារជាមួយអតិថិជនជនជាប់ចោទបានកែប្រែខុសពីការពិតទាំងអស់។ សាលក្រមព្រហ្មទណ្ឌមុនខ្លួនមិនបានប្តឹងឧទ្ធរណ៍ទេ ដោយខុកឌីកាសឱ្យគាត់យកលុយមកសងខ្លួនវិញ មិនចង់ឱ្យគាត់ជាប់គុកទេ។ ចំណុចនេះបានឆ្លុះឱ្យឃើញថា ដើមបណ្តឹងរដ្ឋប្បវេណីបានអនុវត្តសិទ្ធិរបស់ខ្លួនតាមនីតិវិធីច្បាប់ទៅតុលាការមានរដ្ឋប្បវេណីជាសមត្ថកិច្ចរួច ដូចមានបញ្ជាក់ក្នុងសាលក្រមរដ្ឋប្បវេណីលេខ ៣៥ "ឆ" ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៣ របស់សាលាដំបូងខេត្តស្ទឹងឃ្មុំ និងលិខិតបញ្ជាក់ការចូលជាស្ថាពរនៃសាលក្រមលេខ ៨០ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២៣។

៤-ផ្អែកតាមចម្លើយសាក្សីរបស់ជនជាប់ចោទឈ្មោះ [redacted] **ប៉ា**, ឈ្មោះ [redacted] **ជីវ័ន្ត**, ឈ្មោះ [redacted] **ឆៃហ៊ាត** និងចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ប៊ុនថា** ព្រមទាំងកស្តតាងជាឯកសារជាក់បន្ទុកនានាដែលមាននៅក្នុងសំណុំរឿង គឺអាចកំណត់បានថា កាលពីអំឡុងឆ្នាំ២០១៨ ដល់ឆ្នាំឆ្នាំ២០២០ នៅចំណុចភូមិពោធិ៍រោងលិច ឃុំកោងកាង ស្រុកពញាក្រែក ខេត្តស្ទឹងឃ្មុំ ជនជាប់ចោទឈ្មោះ [redacted] ស៊ីណា ពិតជាបានប្រព្រឹត្តបទល្មើស **រំលោភលើទំនុកចិត្តពិសេសដោយអភិបាល** តាមមាត្រា **៣៩១** មាត្រា **៣៩៣** កថាខណ្ឌទី១ នៃក្រមព្រហ្មទណ្ឌ ប្រាកដមែន។

៥-ជារួមមកឃើញថាមានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] **ស៊ីណា** ភេទប្រុស អាយុ៣២ឆ្នាំ (មានសាវតារជាតិដូចខាងលើ) ពីបទ **រំលោភលើទំនុកចិត្តពិសេសដោយអភិបាល** ប្រព្រឹត្តនៅចំណុចភូមិពោធិ៍រោងលិច ឃុំកោងកាង ស្រុកពញាក្រែក ខេត្តស្ទឹងឃ្មុំ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា **៣៩១** មាត្រា **៣៩៣** កថាខណ្ឌទី១ នៃក្រមព្រហ្មទណ្ឌ។

៦-តាមសំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] **ស៊ីណា** បានឆ្លើយថាស្នើសុំឱ្យតុលាការសម្រេចឱ្យខ្លួនរួចផុតពីបទចោទប្រកាន់នោះ តុលាការយល់ឃើញថា ក្រោយពីបានពិនិត្យផ្ទៀងផ្ទាត់ឯកសារជាកស្តតាងនៅក្នុងសំណុំ

Scanned with CamScanner

រឿងឃើញថាតុលាការមិនបានរកឃើញភស្តុតាងណាមួយដែលបញ្ជាក់ថា ជនជាប់ចោទមិនបានប្រព្រឹត្តដូចការចោទប្រកាន់ឡើយ។

៧-តាមរយៈសាលក្រមព្រហ្មទណ្ឌលេខ ១៩០ "គ" ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២១ របស់សាលាដំបូងខេត្តត្បូងឃ្មុំ ឃើញថា បន្ទាប់ពីតុលាការរកឃើញថា មានធាតុផ្សំបទល្មើសគ្រប់គ្រាន់ឈ្មោះ [redacted] ស៊ីណា, ឈ្មោះ [redacted] ភ័, ឈ្មោះ [redacted] ជីវ័ន្ត និងឈ្មោះ [redacted] ឆៃហ៊ាត តុលាការក៏បានសម្រេចផ្តន្ទាទោសលើជនជាប់ចោទ និងបានទុកសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណីទាមទារសំណងរដ្ឋប្បវេណីទៅតុលាការជាសមត្ថកិច្ច។ តាមរយៈនេះ តុលាការពិនិត្យឃើញថា ព្យសនកម្មដែលកើតចេញពីទង្វើរបស់ជនជាប់ចោទម្នាក់ៗមិនទាន់បានញែកចេញជាច់ស្រឡះពីគ្នា ដើម្បីកំណត់អំពីទោសលើជនជាប់ចោទត្រឹមកម្រិតណានោះទេ។ ដូច្នេះគប្បីតុលាការពិនិត្យ និងកែប្រែសេចក្តីសម្រេចសារជាថ្មីលើជនជាប់ចោទឈ្មោះ [redacted] ស៊ីណា ដោយផ្អែកលើហេតុផលដូចតទៅ៖

-តាមការសាកសួរដេញដោលនាពេលសវនាការ និងពិនិត្យលើចម្លើយរបស់សាក្សីឈ្មោះ [redacted] ជីវ័ន្ត បានបញ្ជាក់ថា ខ្លួនបានចូលធ្វើការជាបុគ្គលិក នៅថ្ងៃទី០១ ខែមីនា ឆ្នាំ២០២០ ហើយនៅអំឡុងពេលនោះការប្រមូលលុយទៅទុកជាក់ក្នុងទូដែក និងដាក់ធនាគារ គឺមិនដែលមានបញ្ហាទេ។ លើសពីនេះទៅទៀតនៅពេលសនែករបានចុះមកពិនិត្យម្តងៗ ក៏ពុំមានបញ្ហាអ្វីនោះដែរ។ ចំណុចនេះបានសរបញ្ជាក់ឱ្យឃើញថាប្រតិបត្តិការសាច់ប្រាក់ក្នុងគ្រឹះស្ថានឥណទានជនបទ ធិតិមា ហ្វាយនែន ម.ក សាខាខេត្តត្បូងឃ្មុំ មានលក្ខណៈប្រក្រតី ដោយលុយបានចូលគណនេយ្យរបស់ដើមបណ្តឹងជាធម្មតា។

-នៅពេលដើមបណ្តឹងបញ្ឈប់ជនជាប់ចោទឈ្មោះ [redacted] ស៊ីណា ពីការងារ ដើមបណ្តឹងមិនបានហៅជនជាប់ចោទឱ្យចូលខ្លួនមកដោះស្រាយគ្នារឿងអតិថិជនមិនបានបង់ប្រាក់ជូនដើមបណ្តឹងក្នុងអំឡុងពេលកូវីដនោះទេ។

-បើពិនិត្យលើចំនួនទឹកប្រាក់ដែលដើមបណ្តឹងបានអះអាងថា បាត់បង់ ដើមបណ្តឹងមិនបានរកអ្នកជំនាញខាងផ្នែកហិរញ្ញវត្ថុ(អ្នកជំនាញឯករាជ្យ) ដែលច្បាប់ទទួលស្គាល់មកពិនិត្យ និងវាយតម្លៃពីទំហំព្យសនកម្មដែលបានកើតឡើងនោះឡើយ។

-នៅក្នុងប្រតិបត្តិការសាច់ប្រាក់របស់ដើមបណ្តឹងក្នុងគ្រឹះស្ថានឥណទានជនបទ ធិតិមា ហ្វាយនែន ម.ក សាខាខេត្តត្បូងឃ្មុំ គឺមានលក្ខណៈច្របូកច្របល់។

<u>ហេតុដូច្នេះតិនិច្ឆ័យសេចក្តីៈ</u>

១-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១៩០ "គ" ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២១ របស់សាលាដំបូងខេត្តត្បូងឃ្មុំ ទុកជាបានការដែល លើកលែងសេចក្តីសម្រេចត្រង់ចំណុចទី៤ (១) និងទី៣ដែលត្រូវសម្រេចសារជាថ្មី។

២-ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] **ស៊ីណា** ភេទប្រុស អាយុ៣២ឆ្នាំ (មានសារតាជាតិដូចខាងលើ) ជាក់ពន្ធនាគារកំណត់រយៈពេល **០២ (ពីរ) ឆ្នាំ ប៉ុន្តែទោសនេះត្រូវព្យួរជេម្មតា** ពីបទ **រំលោភលើទំនុកចិត្តពិសេសដោយអភិបាល** ប្រព្រឹត្តនៅចំណុចភូមិពោធិ៍រោងលិច ឃុំកោងកាង ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា **៣៩១** មាត្រា **៣៩៣** កថាខណ្ឌទី១ និងមាត្រា **១០៧** នៃក្រមព្រហ្មទណ្ឌ។

៣-សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០២៣ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២៣ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] **ស៊ីណា** និងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ប៊ុនថា។

បើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

ថ្ងៃពុធ ១១កើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧
ខេត្តត្បូងឃ្មុំ, ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២៣

ក្រឡាបញ្ជីសវនាការ
ហត្ថលេខា និងត្រា៖ [redacted]

ចៅក្រមជំនុំជម្រះ
ហត្ថលេខា និងត្រា៖ [redacted]

បានឃើញ
ចៅក្រមជំនុំជម្រះ
[redacted]

បានចតចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃពុធ ១១កើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧
ខេត្តត្បូងឃ្មុំ, ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២៣
ក្រឡាបញ្ជី
[redacted]

Scanned with CamScanner